**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១០៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលតំបន់អាស៊ីអាគ្នេយ៍ សម្រាប់ការអភិវឌ្ឍអប់រំបច្ចេកទេស

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា/.

- បានឃើញអនុក្រឹត្យលេខ១១៩ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**សម្រេច**

**មាត្រា១ .-**

ត្រូវបានបង្កើតមជ្ឈមណ្ឌលតំបន់អាស៊ីអាគ្នេយ៍សម្រាប់ការអភិវឌ្ឍអប់រំបច្ចេកទេសដែលសរសេរជាអក្សរកាត់ថា ម.ត.អ.ប. និងជាភាសាអង់គ្លេសថា SEAMEO Regional Center for Technical Education Development (SEAMEO TED)។

ម.ត.អ.ប. ស្ថិតក្រោមអាណាព្យាបាលរបស់ក្រសួងអប់រំ យុវជន និងកីឡា។

បច្ចុប្បន្ន ម.ត.អ.ប. មានទីតាំងស្ថិតនៅក្នុងបរិវេណសាលាគរុកោសល្យនិងវិក្រឹតការខេត្តសៀមរាប ក្នុងភូមិព សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប។

**មាត្រា២ .-**

ម.ត.អ.ប. មានតួនាទីជាសេនាធិការឲ្យក្រសួងអប់រំ យុវជន និងកីឡា៖

- លើការអប់រំបច្ចេកទេស អភិវឌ្ឍសមត្ថភាព និងស្រាវជ្រាវសម្រាប់បុគ្គលិកអប់រំ គ្រូបច្ចេកទេស និងគ្រូឯកទេសក្នុងក្របខណ្ឌជាតិនិងអន្តរជាតិ។
- សម្របសម្រួលកិច្ចប្រជុំរបស់ ម.ត.អ.ប. (SEAMEO) តំបន់និងកិច្ចប្រជុំផ្សេងៗទៀត។

**មាត្រា៣ .-**

ម.ត.អ.ប. មានភារកិច្ចដូចខាងក្រោម៖

- ផ្តល់ការអប់រំបច្ចេកទេសកម្រិតមូលដ្ឋាននិងកម្រិតមធ្យមដល់បុគ្គលិកអប់រំ គ្រូបច្ចេកទេស និងគ្រូឯកទេស
- សហប្រតិបត្តិការជាមួយគ្រឹះស្ថានសិក្សាជាតិនិងអន្តរជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នពាក់ពន្ធនានា
- លើកកម្ពស់សមត្ថភាពជំនាញបច្ចេកទេសបុគ្គលិកអប់រំ គ្រូបច្ចេកទេស និងគ្រូឯកទេស
- អភិវឌ្ឍកម្មវិធីអប់រំបច្ចេកទេសស្របតាមតម្រូវការទីផ្សារការងារនិងស្តង់ដាសមត្ថភាព
- ស្រាវជ្រាវនិងបង្កើតប្រព័ន្ធហាត់ការ កម្មសិក្សាបុគ្គលិកអប់រំ គ្រូបច្ចេកទេស និងគ្រូឯកទេសផ្អែកលើនវានុវត្តន៍និងឧត្តមានុវត្តន៍
- គ្រប់គ្រងបុគ្គលិកអប់រំ បុគ្គលិកជាប់កិច្ចសន្យា និងទ្រព្យសម្បត្តិរបស់ ម.ត.អ.ប.
- លើកគម្រោងថវិកាប្រចាំឆ្នាំសម្រាប់កិច្ចដំណើរការរបស់ ម.ត.អ.ប.
- កៀរគរធនធានពីប្រភពផ្សេងៗទៀតសម្រាប់ការបណ្តុះបណ្តាលនិងការស្រាវជ្រាវ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៤ .-**

ម.ត.អ.ប. ត្រូវរៀបចំកម្មវិធីអប់រំបច្ចេកទេសស្របតាមតម្រូវការសមត្ថភាពនិងនៃជំនាញ...ថ្នាក់ជាតិ...ស្រុក និងតំបន់។

យន្តការ នីតិវិធី និងកម្មវិធីអប់រំបច្ចេកទេស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

សិក្ខាកាមដែលបានបញ្ចប់ការសិក្សាដោយជោគជ័យពី ម.ត.អ.ប. ត្រូវទទួលបានលិខិតបញ្ជាក់ការសិក្សាតាមកម្រិតនិងមុខជំនាញដែលបានសិក្សា។

**មាត្រា៥ .-**

ម.ត.អ.ប. ត្រូវដឹកនាំដោយនាយក១(មួយ)រូប ដែលមានឋានៈស្មើប្រធាននាយកដ្ឋាន និងនាយករង២(ពីរ)រូប មានឋានៈស្មើអនុប្រធាននាយកដ្ឋាន។

ម.ត.អ.ប. មានការិយាល័យមួយចំនួនតាមការចាំបាច់។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះ ម.ត.អ.ប. ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៦ .-**

ម.ត.អ.ប. ត្រូវមានក្រុមប្រឹក្សាបច្ចេកទេសមួយ ដើម្បីជួយពិនិត្យ ផ្តល់យោបល់ និងតម្រង់ទិសលើការងារអប់រំបច្ចេកទេសឲ្យស្របតាមគោលនយោបាយផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងកម្មវិធីសិក្សារបស់ ម.ត.អ.ប.។

សមាសភាពនិងភារកិច្ចរបស់ក្រុមប្រឹក្សាបច្ចេកទេសត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៧ .-**

ម.ត.អ.ប. អាចមានទីប្រឹក្សាបច្ចេកទេសនិងអ្នកជំនាញការជាតិនិងអន្តរជាតិមួយចំនួនសម្រាប់ជួយបំពេញការងារ។

ម.ត.អ.ប. មានមន្ត្រីបម្រើការមកពីក្របខណ្ឌមុខងារសាធារណៈ។ ម.ត.អ.ប. មានសិទ្ធិស្នើសុំជ្រើសរើសមន្ត្រីនិងបុគ្គលិកជាប់កិច្ចសន្យាជួយបំពេញការងារ។

នាយក នាយករង មន្ត្រី និងបុគ្គលិកបម្រើការនៅ ម.ត.អ.ប. អាចទទួលប្រាក់លើកទឹកចិត្តបន្ថែមតាមការសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៨ .-**

ម.ត.អ.ប. មានសិទ្ធិប្រើប្រាស់ត្រាដោយឡែកសម្រាប់ដំណើរការការងាររបស់ខ្លួន។

**មាត្រា៩ .-**

ការចំណាយសម្រាប់ដំណើរការរបស់ ម.ត.អ.ប. ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិក្នុងគម្រោងថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា។

ម.ត.អ.ប. មានសិទ្ធិទទួលនិងចាត់ចែង ប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាននូវមូលនិធិដែលបានមកពីប្រភពស្របច្បាប់ផ្សេងៗទៀត សម្រាប់ដំណើរការការងាររបស់ខ្លួន។

**មាត្រា១០ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១១ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ ២០១៧

នាយករដ្ឋមន្ត្រី

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**ហង់ ជួន ណារ៉ុន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ